ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧៧២៣

ចុះថ្ងៃទី០៤-០៩-២០១៣

ជំនុំជម្រះលេខ ១២៣២

ចុះថ្ងៃទី១០-០៤-២០១៧

សាលក្រមលេខ: ៣០៣ ក្រ១០"គ១"

ចុះថ្ងៃទី០៣.០៧.២០១៧

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង០៨ និង០០នាទី ដោយមានសមាសភាពចូលរួមដូចតទៅ ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:២៧២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៣ ដែលមាន៖

-ជនជាប់ចោទឈ្មោះ: [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិនីហ្សេរីយ៉ា កាន់លិខិតឆ្លងដែនលេខ A00៧៨២៤៥៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ទីកន្លែងកំណើតប្រទេសនីហ្សេរីយ៉ា អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះជួល២៣១ ផ្លូវលេខ៤១៦BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជានីតិជន។ (ក្រៅឃុំ)

-មានលោកមេធាវី[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ជាប់ចោទពីបទៈរំលោភសេពសន្ថវៈស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះលេខ១២០ ផ្លូវលេខ១៥(បុរីពិភពថ្មី) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០១៣ និងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ: [redacted] ភេទស្រី អាយុ១១ឆ្នាំ មុខរបរៈសិស្ស ជនជាតិខ្មែរ មានអាសយដ្ឋានផ្ទះលេខ១២០ ផ្លូវលេខ២១៥(បុរីពិភពថ្មី) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

**អង្គហេតុ**

-កាលពីខែឧសភា ឆ្នាំ២០១៣ និងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់មន្ត្រីចុះធ្វើការសម្ភាសន៍កុមារីរងគ្រោះឈ្មោះ [redacted] អ្នកគ្រូឈ្មោះ: [redacted] និងឈ្មោះ: [redacted]នាំយកសាលា មីគីវ៉េ សាខាទី១ ដែលមានទីតាំងនៅតាម

Scanned by CamScanner

បណ្តាលផ្លូវ វេង ស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពាក់ព័ន្ធករណី រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ។ បន្ទាប់ពីទទួលបានការអនុញ្ញាតឲ្យបើកការស៊ើបអង្កេតបឋមពីលោកព្រះរាជអាជ្ញារ[redacted]ការិយាល័យបានចេញលិខិតកោះហៅ ចំនួន០២លើកឲ្យឈ្មោ[redacted] ចូលមកបំភ្លឺតែជននេះមិនព្រមចូលខ្លួនមកបំភ្លឺតាមការកោះហៅ ។

-បានឃើញរបាយការណ៍សំយោគលេខ ២៥៤/១៣ រ.ប.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ របស់ការិយាល័យជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២០២០ អ.យ.ង ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨៥៣ អ.យ.យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១៤២ ៉ប-ជ.ជ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-តាមអំណាចម្លើយជនរងគ្រោះឈ្មោះ [redacted]ានឆ្លើយថា៖ ខ្លួនបានស្នាក់នៅជាមួយអ៊ុំស្រី ដែលមានប្តី ជាជនជាតិស្បែកខ្មៅ ហើយនៅថ្ងៃមួយក្នុងខែឧសភា ឆ្នាំ២០១៣ ពេលដែលអ៊ុំស្រីចេញទៅធ្វើការ អ៊ុំប្រុស ដែលជាជនជាតិស្បែកខ្មៅ បានហៅខ្លួនឲ្យទៅដេកលើពូករបស់គាត់ រួចចាប់អោប ស្ទាបអង្អែលលេងគូទ និងប្រដាប់ភេទរបស់ខ្លួន ហើយគាត់ស្រាតខោអាវចេញអស់ ចាប់ឲ្យខ្លួនដេកផ្ងារ រួចឡើងពោបពីលើ សើយរ៉ូប និងលីអូរបស់ខ្លួនចេញ យកក្ដៅរបស់គាត់ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន ធ្វើចលនារួមភេទ ប្រហែលបីនាទី ខ្លួនឈឺខ្លាំងពេក និងមានឈាមផង គាត់ក៏ឈប់ រួចយកដៃលូកលេងប្រដាប់ភេទរបស់ខ្លួន យ៉ាងយូរទើបឲ្យខ្លួនទៅងូតទឹក ។ ក្រោយមកពេលថ្ងៃត្រង់ ម៉ោងប្រហែល១៣ ខ្លួនកំពុងលាងចាន អ៊ុំប្រុស ដែលជាជនជាតិស្បែកខ្មៅ បានចាប់ខ្លួន ដាក់លើសាឡុង ដាក់ចូលក្នុងប្រដាប់ភេទរបស់ខ្លួន ធ្វើចលនារួមភេទ បឺតដោះរបស់ខ្លួន រហូតចេញទឹកពណ៌សដាក់ប្រដាប់ភេទខ្លួន ទើបឈប់ ហើយនៅវេលាម៉ោងប្រហែល១៥ ពេលខ្លួនកំពុងគេងលើសាឡុង គាត់បានមករួមភេទជាមួយខ្លួនម្តងទៀត ។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង០៧ព្រឹក អ៊ុំស្រីរបស់ខ្លួនយកម៉ូតូចេញទៅមុខផ្ទះ ហើយនិយាយជាមួយអ្នកជិតខាង ស្រាប់តែអ៊ុំប្រុសចាប់ខ្លួនចូលក្នុងបន្ទប់ ហើយរួមភេទជាមួយខ្លួន រួចទើបឲ្យស្លៀកពាក់ទៅសាលា ។

-តាមអំណាចម្លើយរបស់សាក្សីឈ្មោះ [redacted]បានឆ្លើយថា៖ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ខ្លួនបានឮអ្នកគ្រូឈ្មោះ [redacted]ដែលជាគ្រូប្រចាំថ្នាក់របស់សិស្សឈ្មោ[redacted] និយាយថាជនបរទេសស្បែកខ្មៅ ដែលជាអ៊ុំរបស់ឈ្មោះ [redacted]បានចាប់ឈ្មោះ[redacted]រំលោភ លុះដល់ពេលសិស្សចេញពីសាលា ម៉ោងប្រហែល០៥ល្ងាច ខ្លួនក៏បានសាកសួរសិស្សឈ្មោះ [redacted] ហើយនាងបានប្រាប់ខ្លួនទាំងយំផងថា អ៊ុំប្រុសរបស់ខ្លួនជាជនជាតិស្បែកខ្មៅ បានចាប់រំលោភនាងជាច្រើនដង រួចគំរាមមិនឲ្យនាងប្រាប់អ្នកដទៃ រួមទាំងអ៊ុំស្រីផង ។

-តាមអំណាចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល១៧ និង១០នាទី មានអ្នកគ្រូឈ្មោ[redacted]ានមកប្រាប់ខ្លួនថា អ្នកគ្រ[redacted] បានប្រាប់គាត់ថា សិស្សឈ្មោះ [redacted]ទស្រី អាយុ១១ឆ្នាំ ត្រូវបានអ៊ុំប្រុសជនជាតិស្បែកខ្មៅចាប់រំលោភ ។ ក្រោយពេលទទួលបានពត៌មាន ខ្លួនក៏បានហៅសិស្សឈ្មោ[redacted]ក សាកសួរ រួចនាងបានប្រាប់ថានាងស្នាក់នៅជាមួយអ៊ុំស្រីដែលមានប្តីជាជនជាតិស្បែកខ្មៅ ហើយពេលអ៊ុំស្រី

Scanned by CamScanner

មិននៅផ្ទះ អ៊ុំប្រុសដែលជាជនជាតិស្បែកខ្មៅនោះ បានចូលក្នុងបន្ទប់គេង ចាប់ស្រាតខោអាវចេញអស់ រួចចាប់ដៃនាងឲ្យលេងក្តរបស់គាត់នោះ ហើយគាត់បានយកដៃលូកចូលប្រដាប់ភេទរបស់ខ្លួន រួចឡើងពោបពីលើនាងចំនួន០៣ដងមកហើយ គឺពល់ថ្ងៃសៅរ៍ និងអាទិត្យ បន្ទាប់ពីធ្វើការសាកសួររួចខ្លួនក៏រាយការណ៍ជូនសមត្ថកិច្ច ។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមរយៈអង្គសវនាការ ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ , អំណានចម្លើយរបស់សាក្សី និងភស្តុតាងដែលមានក្នុងសំណុំរឿងយល់ឃើញថាៈ ជនជាប់ចោទឈ្មោ[redacted]តជាបានប្រព្រឹត្តនូវអំពើ រំលោភសេពសន្ថវៈស្តានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះលេខ១២០ ផ្លូវលេខ១៥(បុរីពិភពថ្មី) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០១៣ និងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ដូច្នេះតំណាងអយ្យការសម្រេចរក្សាការចោទប្រកាន់ និងប្តឹងសុំឲ្យតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិច្បាប់ ។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ</u>

-លោកមេធាវី[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted]បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងឯកសារពាក់ព័ន្ធ ខ្ញុំបាទជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសូមធ្វើសេចក្តីសន្និដ្ឋានថា ពិតជាមានភាពអយុត្តិធម៌សំរាប់កូនក្តីរបស់ខ្ញុំ ព្រោះឯកសារចេញពីមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានសន្និដ្ឋានបញ្ជាក់ថា ពុំមានស្នាមអ្វីគួរឲ្យកត់សំគាល់ និងពុំមានទឹកកាមរបស់មនុស្សបុរសចូលក្នុងប្រដាប់ជនរងគ្រោះទេ ។ ដូច្នេះស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះឲ្យកូនក្តីរបស់ខ្ញុំបាទ រួចផុតពីការចោទប្រកាន់ ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

-កាលពីអំឡុងខែឧសភា ឆ្នាំ២០១៣ ពិតជាមានករណីៈរំលោភសេពសន្ថវៈស្តានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ កើតឡើងនៅចំណុចផ្ទះលេខ១២០ ផ្លូវលេខ១៥(បុរីពិភពថ្មី) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ បានចាប់ជនរងគ្រោះសើយរ៉ូប និងលីអូរបស់ជនរងគ្រោះ រួចយកប្រដាប់ភេទដាក់ចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ ធ្វើចលនារួមភេទប្រហែលបីនាទីទើបឈប់ ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ជនជាប់ចោទបានធ្វើសកម្មភាពម្តងទៀត ដោយចាប់ជនរងគ្រោះចូលក្នុងបន្ទប់រួចរួមភេទ ទើបឲ្យជនរងគ្រោះទៅសាលា ប្រាកដមែន ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោ[redacted]តជាបានបញ្ជាក់ថា ជាជនជាតិស្បែកខ្មៅឈ្មោះ [redacted]ភេទប្រុស បានចាប់ជនរងគ្រោះរួមភេទ ក្នុងខែឧសភា ឆ្នាំ២០១៣ និងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង០៧ព្រឹក ប្រាកដមែន ។

Scanned by CamScanner

-ផ្អែកតាមអំណានចម្លើយរបស់ជនរងគ្រោះ , អំណានចម្លើយរបស់សាក្សី និងភស្តុតាងដែលសមត្ថកិច្ចប្រមូលបានដាក់ក្នុងសំណុំរឿង មានលក្ខណៈស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted]ភេទប្រុស អាយុ៣៧ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ប្រាកដមែន ។

-អំពើ និងសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិហ្វេរីយ៉ា ពិតជាមានចេតនា បញ្ចូលអង្គជាតរបស់ខ្លួន ទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើជនរងគ្រោះដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ដែលអំពើនេះផ្ទុយទៅនឹងបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសន្និដ្ឋានះសុំឲ្យតុលាការលើកលែងការចោទប្រកាន់ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ គឺតំកល់ការចោទប្រកាន់ទុកនៅដដែល ។

-មានពិរុទ្ធភាព គ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិហ្វេរីយ៉ា ពីបទៈរំលោភសេពសន្ថវៈស្មានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះលេខ១២០ ផ្លូវលេខ១១៥(បុរីពិភពថ្មី) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០១៣ និងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

**<u>ហេតុដូច្នេះសម្រេច</u>**

-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិនៅហ្វេរីយ៉ា ដាក់ពន្ធនាគារ កំណត់រយៈពេល ១០ឆ្នាំ(ដប់ឆ្នាំ) ពីបទៈរំលោភសេពសន្ថវៈស្មានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះលេខ១២០ ផ្លូវលេខ១១៥(បុរីពិភពថ្មី) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០១៣ និងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះធ្វើឡើងដោយឆ្លងកាត់ការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ[redacted], ជនរងគ្រោះឈ្មោះ[redacted] ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted]និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ ។

-បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា[redacted] |

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

- បានចម្លងត្រឹមត្រូវតាមច្បាប់ដើម -

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

[redacted]

Scanned by CamScanner